# របាយការណ៍វឌ្ឍនភាពស្តីពី
# លទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច
# ប្រចាំឆ្នាំ២០១៩

## ផ្នែកទី១-I ៖ ព័ត៌មានជាមូលដ្ឋានរបស់ក្រុមហ៊ុន

១-ក្រុមហ៊ុនឈ្មោះ ៖ ហ្រ្គែនឌីស ធីមប៊ើរ អិលធីឌី (Grandis Timber Ltd)

២-ក្រុមហ៊ុនមកពី ៖ ក្នុងស្រុក ☐ ឬបរទេស ☑ មកពីប្រទេស ដាណឺម៉ាក់

៣-ឈ្មោះនាយករបស់ក្រុមហ៊ុន ៖ លោក **Timothy Andrew FLEMING** ជនជាតិនូវែលសេឡង់

៤-ស្នាក់ការក្រុមហ៊ុន ៖ ស្នាក់ការកណ្តាល (ផ្ទះលេខ ៣៨ដេ ផ្លូវ ៤៩៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចម្ការមន ក្រុងភ្នំពេញ)
ស្នាក់ការរងប្រចាំខេត្ត (ភូមិដូង ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ)

៥-ទីតាំង និងទំហំផ្ទៃដី ៖ ឃុំ ក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច និងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ទំហំផ្ទៃដី ៧ ៨៩៦,១១ ហិកតា

៦-កម្មវត្ថុវិនិយោគ ៖ បង្កើតកសិដ្ឋានដាំដើមឈើម៉ៃសាក់ និងសាងសង់រោងចក្រកែច្នៃ

៧-កិច្ចសន្យាវិនិយោគ ៖ មាន ☑ ឬ គ្មាន ☐

- កិច្ចសន្យាកែតម្រូវចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ដោយកែតម្រូវផ្ទៃដីត្រឹម ៧៨៩៦,១១ ហិកតា និងរយៈពេល ៥០ឆ្នាំ
- កិច្ចសន្យាដើមចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៩ សម្រាប់រយៈពេល៧០ឆ្នាំលើផ្ទៃដី ៩ ៨២០ ហិកតា ដើម្បីវិនិយោគដាំដំណាំឈើម៉ៃសាក់ ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៨-ប្រាក់កក់ធានាកិច្ចសន្យា ៖ បានបង់ ☑ ចំនួន **៩ ៨២០០ ដុល្លារអាមេរិក** លេខវិក័យប័ត្រ ១២៣០៤៥ បង់ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១០

៩-ការចុះបញ្ជីដីរដ្ឋ ៖

- បានអនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (វិញ្ញាបនប័ត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ចំនួន១៧ ប័ណ្ណ)
- កំពង់អនុវត្ត ☐

១០-អនុបយោគ ៖

- បានអនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (អនុក្រិតលេខ១៧៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦)
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ

១១-ការបង់ថ្លៃឈ្នួលសម្បទាន ៖

- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩ (២០១៩-២០២០) នូវទឹកប្រាក់ចំនួន **៤១.០៨៣,៦១ ដុល្លារអាមេរិក** នៅធនាគាជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី (ជូនភ្ជាប់សក្ខីយប័ត្របង់ប្រាក់ ២ ច្បាប់)
- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៨ (២០១៧ - ២០១៨) នូវទឹកប្រាក់ចំនួន **៤០ ៦៧៦,៨៤ ដុល្លារអាមេរិក** នៅធនាគាជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី (សក្ខីយប័ត្របង់ប្រាក់ ២ ច្បាប់បានផ្តល់ជូន)
- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៧ (២០១៦-២០១៧) លើទំហំទឹកប្រាក់ចំនួន **៤០ ២៧៤,១០ ដុល្លារអាមេរិក** នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី (សក្ខីយប័ត្របង់ប្រាក់ ២ ច្បាប់ បានផ្តល់ជូន)
- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចចំនួន០២ឆ្នាំសម្រាប់ឆ្នាំ២០១៥(២០១៤-២០១៥) និង២០១៦(២០១៥-២០១៦) ចំនួនទឹកប្រាក់ **៧៩ ៣៥៥,៩០ដុល្លារអាមេរិក** នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ នៅធនាគារជាតិនៃកម្ពុជា និង ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ នៅធនាគារកាណាឌីយ៉ា ក.អ កម្ពុជា (សក្ខីយប័ត្របង់ប្រាក់ ២ ច្បាប់ បានផ្តល់ជូន)

១២-របាយការណ៍ ESIA ៖

- បានអនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ៖ របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ត្រូវក្រសួងបរិស្ថានអនុម័តរួចរាល់ តាមលិខិតលេខ ១៥៦២ សជណ.បស្ក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩។
- បានអនុវត្តរួចរាល់ ESIA បឋម មាន ☑៖ លិខិតលេខ ១៧២ ស.ជ.ណ ប.ស្ក ចុះថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០១៤ របស់ក្រសួងបរិស្ថាន

១៣-ការឯកភាពលើផែនការមេ ៖

- ផែនការមេកែមត្រូវកំពុងដំណើរៈ ការពិនិត្យ និងពិភាក្សា លើធាតុចូលបច្ចេកទេសត្រូវបានបញ្ចប់រវាងក្រុមហ៊ុន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បានដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាលើកទី៤ ដើម្បីពិនិត្យ និងផ្តល់យោបល់ ដោយអនុលោមតាមខ្លឹមសារកំណត់ហេតុប្រជុំថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ និង ស្មារតីកិច្ចប្រជុំបបច្ចេកទេស (ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១) រវាងក្រុមហ៊ុន និងនាយកដ្ឋានផែនការ និងស្ថិតិ របស់ក្រសួង។
- មាន ☑ គ្មាន ☐ ឯកភាពដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមលិខិតលេខ ៣២៥៩/៣៣៦ កសក. រផ.ផក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១៤-ការអនុញ្ញាតឱ្យឈូសឆាយ ៖

- មាន ☑ គ្មាន ☐ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លិខិតលេខ. ១៨៨ កសក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ អនុញ្ញាតឲ្យឈូសឆាយក្នុងអនុតំបន់ទី៧ ៨ ៩ និង១០ លើផ្ទៃដីទំហំ ១២១២ ហិកតា
- លិខិតលេខ ៤០១២/២៤៦ កសក. រផ.ផក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុញ្ញាតឲ្យឈូសឆាយក្នុងអនុតំបន់ទី៧ និង៨ លើផ្ទៃដីទំហំ ២០០០ ហិកតា
- លិខិតលេខ ៣២៥៩/៣៣៦ កសក. រផ.ផក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុញ្ញាតឲ្យឈូសឆាយក្នុងអនុតំបន់ទី១ លើផ្ទៃដីទំហំ ៥០០ ហិកតា

១៥-ប្រវត្តិសមាសភាពក្រុមហ៊ុន ៖

- មាន ☑ គ្មាន ☐ បើមានស្នើអត្ថាធិប្បាយ (ក្រុមហ៊ុនហ្គ្រេនឌីស ធីមប៊ើរ អិលធីឌី ជាក្រុមហ៊ុន អន្តរជាតិវិនិយោគលើការអភិវឌ្ឍន៍ចម្ការឈើម៉ៃសាក់សម្រាប់គោលបំណងពាណិជ្ជកម្ម លើសម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងស្រុកចំនួន០២ គឺ ស្រុកភ្នំស្រួច និងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ លើផ្ទៃដីចុះបញ្ជី និងរៀបចំងនុបយោគរួចទំហំ **៧៨៩៦,១១ ហិកតា**។

១៦-លេខទូរស័ព្ទទំនាក់ទំនងជាមួយតំណាងក្រុមហ៊ុន និងប្រចាំការរបស់ក្រុមហ៊ុននៅការដ្ឋានដាំដុះ៖

- លេខទូរស័ព្ទ៖ ០២៣ ២២២ ១៧៣/០១៧ ៦៦៦ ៤២៣
- លេខ អ៊ីមែល៖ info@grandistimber.com
- អាស័យដ្ឋាន៖ លេខ ៣៨ដេ ផ្លូវ ៤៩៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចម្ការមន ក្រុងភ្នំពេញ

## ផ្នែកទី២-II ៖ ផែនការប្រើប្រាស់ដី និងវឌ្ឍនភាពនៃការអនុវត្តកិច្ចសន្យា និងផែនការមេរបស់គម្រោងវិនិយោគ

### ១-ផែនការប្រើប្រាស់ដីក្នុងផែនការមេ (ខ្នាតគិតជាហិកតា)

| ឆ្នាំ | អនុតំបន់ | ផ្ទៃដីសរុបតាមផែនទី | ផ្ទៃដីដែលត្រូវកាត់ចេញ | | | | ផ្ទៃដីសម្រាប់ធ្វើអាជីវកម្ម |
|---|---|---|---|---|---|---|---|
| | | | ផ្ទៃដីរក្សាទុក | ទីទ្រនាប់អូរ | ទីជម្រាល | ដីពាក់ព័ន្ធប្រជាជន | |
| ២០១០ | ១ | ១៦៣,៩២ | ០,៨៨ | ១១,២០ | ០០ | ០០ | ១៥១,៨០ |
| ២០១១ | ២ | ៤៥១,០៥ | ៤២,៥១ | ៤២,៣០ | ០០ | ០០ | ៣៦៦,២៣ |
| ២០១២ | ៣ | ៥៤៩,២៥ | ០,៨៨ | ២៧,៦០ | ០០ | ០,៩០ | ៥១៩,៩១ |
| ២០១៣ | ៤ | ៧២៩,៦៧ | ៤៤,១០ | ៣៩,៩០ | ០០ | ១,៦០ | ៦៤៤,០៩ |
| ២០១៤ | ៥ | ៧៦៦,៤៤ | ៦១,១៥ | ៤៥,០០ | ០០ | ១,១០ | ៦៥៩,២៥ |
| ២០១៥ | ៦ | ៩៣០,២៦ | ៩១,៨៧ | ៦៩,១០ | ០០ | ០,២០ | ៧៦៩,១៦ |
| ២០១៦ | ៧ | ៨៩៧,៦២ | ០,៩២ | ១០១,៣០ | ០០ | ០០ | ៧៩៥,៤៤ |
| ២០១៧ | ៨ | ៧៦២,៥៥ | ១,៨១ | ៤៣,៦០ | ០០ | ០០ | ៧១៧,១៩ |
| ២០១៨ | ៩ | ១០៦២,៦៤ | ១,៨៧ | ៨៨,២០ | ០០ | ០០ | ៩៧២,៦១ |
| ២០១៩ | ១០ | ១៥៨២,៧១ | ២៥,១៤ | ១១១,៧០ | ០០ | ០០ | ១៤៤៥,៩១ |
| **សរុប** | | **៧៨៩៦,១១** | **២៧១,១៣** | **៥៧៩,៧២** | **០០** | **៣,៧១** | **៧០៤១,៥៩** |

## ២-លទ្ធផលអនុវត្តបាន (ខ្នាតគិតជាហិកតា)

### ២.១-លទ្ធផលអនុវត្តបានក្នុងឆ្នាំកន្លងមក

| ឆ្នាំ | អនុតំបន់ | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដី អនុញ្ញាត (ហ.ត) | ផ្ទៃដីអនុវត្តបាន (ហ.ត) | | | | ផ្ទៃដីនៅសល់ | មូលហេតុ |
|---|---|---|---|---|---|---|---|---|---|
| | | | | ប្រភេទដំណាំ | ផ្ទៃដីឈូសឆាយ | ផ្ទៃដីបានដាំដុះ | ដាំដុះឡើងវិញ | (ហ.ត) | |
| 2010 | 1,3,6 | 151.8 | 407 | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 93.62 | 30.3 | 0 | 63.32 | |
| 2011 | 1,2,3,4,6,7 | 366.23 | 0 | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 1379.82 | 1430.61 | 0 | -50.79 | |
| 2012 | 2,3,4,5 | 551.91 | 0 | ម៉ៃសាក់និងប្រភេទផ្សេងៗ | 372.91 | 359.82 | 0 | 13.09 | |
| 2013 | 5,6,7,8,9 | 644.09 | 2000 | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 1700 | 1622.76 | 0 | 77.33 | |
| 2014 | 8,9,10 | 659.25 | 0 | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 1479.1 | 434.77 | 0 | 1044.33 | |
| 2015 | 8,9 | 769.16 | 0 | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 0 | 487.24 | | -483.32 | |
| 2016 | 1,5,7,9,10 | 795.44 | 0 | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 0 | 483.32 | 0 | 0 | |
| 2017 | ចម្ការចាស់ឆ្នាំ២០១៣ | | 0 | ម៉ៃសាក់ ប្រភេទឈើផ្សេងៗ | 0 | 0 | 96.49 | 0 | |
| 2017 | | | 0 | អំពៅ | 0 | 0 | 105.77 | 0 | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 2018 | 10 | | 1212 | ម៉ៃសាក់និងប្រភេទផ្សេងៗ | 441.75 | 253.69 | 0 | 188.69 | |
| សរុប | | | 3619 | | **5467.20** | **5102.51** | **202.26** | **852.65** | |

## ២.២-លទ្ធផលអនុវត្តបានក្នុងឆ្នាំ២០១៩

| ឆ្នាំ | អនុតំបន់ត្រូវអនុវត្ត | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដី អនុញ្ញាត (ហ.ត) | ផ្ទៃដីអនុវត្តបាន (ហ.ត) | | | ផ្ទៃដីនៅសល់ (ហ.ត) | មូលហេតុ |
|---|---|---|---|---|---|---|---|---|
| | | | | ប្រភេទដំណាំ | ផ្ទៃដីឈូសឆាយ | ផ្ទៃដីបានដាំដុះ | | |
| ២០១៩ | ៤, ៥, ១០ | ១៥៨២.៧១ | 0 | ម៉ៃសាក់ ប្រេងខ្យល់ អាកាស្យា គីនីន | 0 | ៩៣.២៧ | 0 | ដាំដុះលើដីចាស់ |
| **សរុប** | | | | | **0** | **៩៣.២៧** | **0** | |

### ២.៣-ការប្រមូលផល

| ឆ្នាំ | អនុតំបន់ប្រមូលផល | ទំហំផ្ទៃដីដាំដុះ | ប្រភេទដំណាំ | ទិន្នផល/១ហិកតា | ទិន្នផលសរុប |
|---|---|---|---|---|---|
| - | - | - | - | - | - |
| **សរុប** | - | - | - | - | - |

(ស្នើបញ្ជាក់ចំណុចនិយាមការទីតាំងដាំដុះ និងប្រមូលផលដែលបានបង្ហាញក្នុងតារាងខាងលើ ដោយភ្ជាប់ផែនទីតំបន់ដាំដុះ)

## ៣-ការប្រើប្រាស់ផល និងផលិតផល៖

| ឆ្នាំ | ប្រភេទដំណាំ | បរិមាណផល-ផលិតផលទទួលបាន | | បរិមាណផល-ផលិតផលនាំចេញ | | បរិមាណផល-ផលិតផលប្រើប្រាស់ក្នុងស្រុក | |
|---|---|---|---|---|---|---|---|
| | | ផល | ផលិតផល | ផល | ផលិតផល | ផល | ផលិតផល |
| - | - | - | - | - | - | - | - |
| **សរុប** | - | - | - | - | - | - | - |

## ៤-ការសាងសង់ក្នុងតំបន់សម្បទាន ៖

| ល.រ | សំណង់ | ឆមាសទី១(ម) | ឆមាសទី២ (ម) | ចំនួន | អនុតំបន់ | ទំហំសរុប(ម)$^{២}$ឬ(គ.ម) | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| ១ | សាងសង់ផ្លូវក្នុងតំបន់សម្បទាន | ៧១០ | 0 | 0២ | ៦, ៧ | 0,៧១ | 0,៧១ គ.ម |
| ២ | ជួសជុលផ្លូវក្នុងតំបន់សម្បទាន | ៥៣៨៥0 | 0 | ១0 | ៣, ៤, ៥, ៦, ១0 | ៥៣,៨៥ | ៥៣,៨៥ គ.ម |

**៥-ការប្រមូលសំណល់ឈើ និងការបង់ថ្លៃឈើបានមកពីការឈូសឆាយក្នុងតំបន់សម្បទាន ៖**

**៥.១-បរិមាណឈើបានមកពីការឈូសឆាយក្នុងតំបន់សម្បទាន**

| ឆ្នាំ | ឈើមូល (ម$^{៣}$) | កូនឈើ (ដើម) | អុស (ស្ទែរ) |
|---|---|---|---|
| ឆមាសទី១ | - | - | - |
| ឆមាសទី២ | - | - | - |
| **សរុបប្រចាំឆ្នាំ** | - | - | - |

**៥.២-បរិមាណឈើបានមកពីការឈូសឆាយក្នុងតំបន់សម្បទាន**

| ឆ្នាំ | ថ្លៃឈើមូល | | | ថ្លៃកូនឈើ | | | ថ្លៃអុស | | | ថ្លៃសរុប |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | បង់រួច | មិនទាន់បង់ | សរុប | បង់រួច | មិនទាន់បង់ | សរុប | បង់រួច | មិនទានបង់ | |
| ឆមាសទី១ | - | - | - | - | - | - | - | - | - | - |
| ឆមាសទី២ | - | - | - | - | - | - | - | - | - | - |
| **សរុបប្រចាំឆ្នាំ** | - | - | - | - | - | - | - | - | - | - |

**៦-ប្រភេទគ្រឿងចក្រ បរិក្ខា រនិងថាមពល ៖**

| ប្រភេទ | បរិយាយ | បរិមាណ (គ្រឿង) | គុណភាព | ផ្សេងៗ |
|---|---|---|---|---|
| បរិក្ខារ និងមធ្យោបាយ | ម៉ាស៊ីនចម្រុះទឹកស្អាត | ១ | ធម្យម | |
| | ម៉ាស៊ីនពន្លត់ភ្លើងព្រៃ | ៥ | មធ្យម | |
| | ឡានដឹក Hyandai Mighty | ៦ | មធ្យម | |
| | ម៉ូតូ | ២៤ | មធ្យម | |

| | | | | |
|---|---|---|---|---|
| | រថយន្ត Tacoma (2001) | ៣ | ធម្យម | |
| | លិកស៊ីស ៤៧០ | ១ | ធម្យម | |
| | Toyota 4Runner | ១ | ធម្យម | |
| | Mini bus 29 seats | ១ | ធម្យម | |
| | | | | |
| គ្រឿងចក្រ | ត្រាក់ទ័រភ្លួរ | ៧ | ធម្យម | |
| | ឡានដឹកដី | ២ | ធម្យម | |
| | ឡានស្ទួច | ១ | ធម្យម | |
| | រ៉ូឡូ | ១ | ធម្យម | |
| | Grader Komatsu | ១ | ធម្យម | |
| | Bulldozer ShantuiD20P SD16L | ១ | ធម្យម | |
| | Excavator -R220LC-9SH #11 | ១ | ធម្យម | |
| ថាមពល | ម៉ាស៊ីនបូមទឹក | ៣៤ | ធម្យម | |
| | ម៉ាស៊ីនភ្លើង | ៩ | ធម្យម | |

## ៧-ការប្រើប្រាស់កំលាំងពលកម្ម ៖

| ឆ្នាំ | កម្លាំងពលកម្ម | ចំនួន (នាក់) | ប្រាក់បៀវត្ស នាក់/ខែ | សម្ភារៈឧបត្ថម្ភបន្ថែម |
|---|---|---|---|---|
| ឆមាសទី១ | បុគ្គលិកខ្មែរ | ១១៧ | ៣១៤,៤៦ ដុល្លារអាមេរិក | |
| | បុគ្គលិកបរទេស | ០១ | ៨៥០០ ដុល្លារអាមេរិក | |
| | កម្មករខ្មែរអចិន្ត្រៃយ៍ | | | |
| | កម្មករបរទេស | | | |
| | កម្មករបណ្តោត | ១៦១ | ១១០ ដុល្លារអាមេរិក | |
| ឆមាសទី២ | បុគ្គលិកខ្មែរ | ១០៨ | ៣៣០ ដុល្លារអាមេរិក | |

| | | | | |
|---|---|---|---|---|
| | បុគ្គលិកបរទេស | ០១ | ៨៥០០ ដុល្លារអាមេរិក | |
| | កម្មករខ្មែរអចិន្ត្រៃយ៍ | | | |
| | កម្មករបរទេស | | | |
| | កម្មករបណ្តែត | ១៥៥ | ១២៣,២០ ដុល្លារអាមេរិក | |
| ប្រចាំឆ្នាំ | បុគ្គលិកខ្មែរ | ៥៣ | ៤៧០ ដុល្លារអាមេរិក | |
| | បុគ្គលិកបរទេស | ០១ | ៨៥០០ ដុល្លារអាមេរិក | |
| | កម្មករខ្មែរអចិន្ត្រៃយ៍ | | | |
| | កម្មករបរទេស | | | |
| | កម្មករបណ្តែត | ១០៤ | ១៥៤ ដុល្លារអាមេរិក | តម្លៃ៧ដុល្លារអាមេរិក/ថ្ងៃ |

**បញ្ជាក់**៖ -តម្រូវការកម្លាំងពលកម្មអតិបរមាតាមរដូវកាលពីខែ.....មិថុនា...ដល់ខែ.....សីហា....

-កម្លាំងពលកម្មពីខេត្តណាខ្លះ? កំពង់ស្ពឺ, តាកែវ, កំពត, បាត់ដំបង

**៨-ការវាយតម្លៃលើការអនុវត្តគម្រោងទាំងមូល ៖**

- តាមពេលកំណត់ ☐
- មុនពេលកំណត់ ☐
- យឺតជាងពេលកំណត់ ☑ (ក្រុមហ៊ុនអនុវត្តយឺតជាងផែនការមេដែលបានកំណត់ប្រមាណ **៩,២៩%** ដោយសារការអនុញ្ញាត្តឱ្យយឺត)
- មិនបានចាប់ផ្តើម ☐
- ត្រូវតាមផែនការមេ ☐
- មិនតាមផែនការមេ ☐
- ត្រូវបានបញ្ចប់គម្រោងទាំងមូល ☐

*សូមគូសញ្ញា(≈) ក្នុងប្រអប់ រួចបញ្ជាក់ពីមូលហេតុ និងបញ្ហាដែលបានលើកឡើង*

**ផ្នែកទី៣-III ៖ ទំនាស់ដីធ្លី និងការដោះស្រាយ មាន ☑ គ្មាន ☐ បើមានស្នើអត្ថាធិប្បាយ៖**

**ក. ទីតាំងទំនាស់ស្ថិតនៅអនុតំបន់ណា? ទំហំដីទំនាស់ប៉ុន្មានហិកតា? ត្រង់ចំណុចនិយាមកា?**

ចំនួនបញ្ហាដីធ្លីសរុបដែលបានកើតឡើងនៅក្នុងតំបន់សម្បទាន និងតំបន់អភិរក្សា (ស្តារឡើងវិញ) មានចំនួន ១១៦ ករណី ក្នុងនោះបញ្ហាដីធ្លីចំនួន ១០៨ ករណី បណ្តាលមកពីការអនុវត្តដំណើរការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ក្នុងភូមិសាស្ត្រឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ និង០៨ ករណី ផ្សេងទៀតកើតឡើងនៅក្នុងភូមិសាស្ត្រឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ទំហំផ្ទៃដីដែលមានផលប៉ះពាល់ក្នុងភូមិព្រៃធំ ឃុំរស្មីសាមគ្គី សរុបមានចំនួន ១៥៩,៦៣ ហិកតា ស្ថិតនៅក្នុងតំបន់សម្បទាន និងតំបន់អភិរក្ស (តំបន់ស្តារ និងតំបន់ទ្រនាប់អូរ)។ ដោយឡែក ផលប៉ះពាល់ដែលស្ថិតនៅក្នុងភូមិសាស្ត្រឃុំក្រាំងដីវ៉ាយ ភាគច្រើនជាទំនាស់ព្រំប្រទលរវាងតំបន់សម្បទានដីសេដ្ឋកិច្ច និងដីឯកជន (*ជូនភ្ជាប់ផែនទីតំបន់ទំនាស់*)។

**ខ. ថ្ងៃ ខែ ឆ្នាំ កើតទំនាស់ (មូលហេតុនៃទំនាស់ និងឯកសារពាក់ព័ន្ធ)**

បញ្ហាដីធ្លីចំនួន ១០៨ ករណី ស្ថិតក្នុងភូមិសាស្ត្រឃុំរស្មីសាមគ្គី ត្រូវបានកើតដោយសារការអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ នៅក្នុងអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩។ ប៉ុន្តែ បញ្ហា០៨ ករណី ផ្សេងទៀត បានរកឃើញខណៈដែលក្រុមហ៊ុនធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ច។ បញ្ហាដីធ្លីដែលស្ថិតនៅភាគខាងត្បូងកើតឡើងដោយសារកំណត់សម្គាល់ព្រំប្រទល់មិនច្បាស់លាស់រវាងសម្បទានដីសេដ្ឋកិច្ច និងដីឯកជនត្រង់តំបន់ដែលមិនទាន់ដាំដុះដើមឈើ។ ទោះបីជាយ៉ាងណាក៏ដោយ ទាំងតំបន់សម្បទានដីសេដ្ឋកិច្ច និងឯកជនសុទ្ធតែមានប្លង់ (រឹង) ដូចគ្នា។ ដោយឡែក បញ្ហាដីធ្លីកើតឡើងនៅភាគខាងជើងបានកើតឡើងក្នុងអំឡុងពេលអនុវត្តការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលបញ្ហាដីធ្លីមានរហូតដល់ ១០៨ ករណី ក្នុងនោះ ០៦ ករណី បានដោះស្រាយរួចរាល់តាំងឆ្នាំទៅ។ ប្រជាជនមានតែបង្កាន់ដៃទទួលស្គាល់សិទ្ធិ (បញ្ជាក់ដោយអាជ្ញាធរឃុំ)។

**គ. វិធានការដោះស្រាយ និងលទ្ធផលដោះស្រាយ**

ចំពោះករណីបញ្ហាដីធ្លីទាំងអស់ត្រូវបានធ្វើការកំណត់នូវឫសគល់នៃបញ្ហា និងកត់ត្រានៅក្នុងតារាងតាមដានបញ្ហារបស់ក្រុមហ៊ុន។ នៅក្នុងដំណើរការកំណត់ឫសគល់នៃបញ្ហានៃទំនាស់ដីធ្លីនីមួយៗ ក្រុមហ៊ុនធ្វើឡើងដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន (ភូមិ ឃុំ) រដ្ឋបាលព្រៃឈើ ប្រជាជនពាក់ព័ន្ធដើម្បីពិនិត្យផលប៉ះពាល់ជាក់ស្តែងនៅទីវាល ប្រមូលឯកសារនៃការកាន់កាប់ដីធ្លី និងឯកសារពាក់ព័ន្ធផ្សេងទៀត។ ក្នុងរយៈពេល ០៩ ខែ/ឆ្នាំ២០១៩ នេះ ក្រុមហ៊ុនមិនត្រឹមតែបានធ្វើការដោះស្រាយ សម្របសម្រួលបញ្ហាដីធ្លីក្រៅប្រព័ន្ធច្បាប់ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុវត្តច្បាប់ក្នុងកម្រិតមូលដ្ឋានដូចខាងក្រោម៖

- ដាក់បណ្តឹងទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងស្ថាប័នពាក់ព័ន្ធ ជំទាស់លើលទ្ធផលនៃវិនិច្ឆ័យក្បាលដីសម្រាប់ចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

- បានជួបប្រជុំជាមួយប្រធានក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធថ្នាក់ស្រុក ដើម្បីស្វែងយល់ពីបញ្ហានិងកំណត់ទិសដៅដោះស្រាយបន្ត។
- ក្រុមហ៊ុនបានកំណត់មុខសញ្ញាអ្នកទាមទារ ទីតាំងទាមទារ (ទំនាស់) និងផែនទី ដើម្បីមានមូលដ្ឋានក្នុងរាយការណ៍ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានអន្តរាគមន៍។
- ក្រុមហ៊ុនបានធ្វើរបាយការណ៍ស្តីពីបញ្ហាដីធ្លីទាំង១១៦ករណីនេះទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ ដើម្បីអន្តរាគមន៍ និងមានវិធានការ។

**ផ្នែកទី៤**-IV ៖ **ការកាត់ឆ្វៀលដីបទបញ្ហា ០១ និងការអនុវត្តខ្លឹមសារ សជណ១៖**

**១-ការកាត់ឆ្វៀល៖**

- ✓ ទំហំដីកាត់ឆ្វៀលតាមបញ្ជា (០១បប និងកាត់ឆ្វៀលក្នុងអំឡុងពេលចុះបញ្ជីដីរដ្ឋ) សរុប **៦០៧,២១ ហិកតា** នៅក្នុងអនុតំបន់ ១ ដល់ ៦
- ✓ ទំហំដីកាត់ឆ្វៀលចេញនៅភាគខាងជើងសម្បទានដីសេដ្ឋកិច្ច ៣០៨,៩៤ ហិកតា ក្នុងអនុតំបន់ទី១០
- ✓ ប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចរបស់ LYP ទំហំ ១២០,៧០ ហិកតា ក្នុងអនុតំបន់ទី ៨
- ✓ តំបន់យកគ្រួសក្រសហម ២១៩,៧៤ ហិកតា ក្នុងអនុតំបន់ទី៧
- ✓ សម្បទានសង្គមកិច្ច ១៩០,៧៩ ហិកតា ក្នុងអនុតំបន់ទី៧
- ✓ តំបន់ការពារប្រភពទឹក ៤៧៦,៤៥ ហិកតា ក្នុងអនុតំបន់ទី ១ ដល់ ១០
- ✓ ទំហំដីនៅសល់ជាក់ស្តែងក្នុងតំបន់សម្បទានទំហំ **៧៨៩៦,១១** ហិកតា (ជូនភ្ជាប់វិញ្ញាបនប័ត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ១៧ប័ណ្ណ)

**២-លទ្ធផលអនុវត្តខ្លឹមសារ សជណ តាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួង៖**

| លេខលិខិត សជណ | ខ្លឹមសារសម្រេចរបស់ ស.ជ.ណ | លទ្ធផលអនុវត្តបានតាមខ្លឹមសារ សជណ |
|---|---|---|
| លិខិតលេខ. ១០៨៤ សជណ ចុះថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី | អនុញ្ញាតអោយក្រុមហ៊ុនហ្វ្រែនឌីសធីមប៊ើរ អិលធីឌី បន្តនីតិវិធីដោះស្រាយផលប៉ះពាលជា មួយប្រជាជន និងចុះកិច្ចសន្យាឡើងវិញដោយបន្ថយ | • បានចុះបញ្ជីដីរួចរាល់<br>• ធ្វើអនុបយោគរួចរាល់ពីដីសាធារណៈ មកជាដីឯកជនរបស់រដ្ឋ |

| | | |
|---|---|---|
| | រយៈពេលពី៧០មកត្រឹម ៥០ឆ្នាំវិញ | • ចុះកិច្ចសន្យាកែតម្រូវ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧<br>• កំពុងដំណើរការពិនិត្យ កែតម្រូវផែនការមេ និងស្នើសុំការអនុម័តលើផែនការមេ |

**ផ្នែកទី៥-V ៖ ការអនុវត្តបន្ទាប់ពីការណែនាំរបស់ក្រសួង ៖**

| ល.រ | លេខលិខិត និងខ្លឹមសារ | លទ្ធផលអនុវត្តបានតាមការណែនាំរបស់ក្រសួង |
|---|---|---|
| ១ | លិខិតលេខ ៣៣១៦/៣៥៩ កសក.ហគ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ស្ដីពីសំណើបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩ នូវទឹកប្រាក់សរុបចំនួន ៤១.០៨៣, ៦១ ដុល្លារអាមេរិក (សែសិបមួយពាន់ប៉ែតសិបបីដុល្លារអាមេរិក និងហុកសិបមួយសេន) | • បង់ចូលធនាគារជាតិនៃកម្ពុជាចំនួន ៣៩.៨៥១,០០ ដុល្លារអាមេរិក ថ្ងៃទី២៤ ខែឧសភា ឆ្នា២០១៩<br>• បង់ចូលធនាគារ អេស៊ីលីដា ភីអិលស៊ី ចំនួន ១.២៣២,៥១ ដុល្លារអាមេរិក នៅថ្ងៃទី១០ ខែឧសភា ឆ្នា២០១៩ |
| ២ | លិខិតលេខ. ៧៥១៤ កសក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០១៧ករណីសំណើរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឲ្យបានរួចរាល់តាមនីតិវិធី | ក្រសួងបរិស្ថានបានអនុម័តរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ សម្រាប់គម្រោងវិនិយោគដាំដើមម៉ៃសាក់របស់ក្រុមហ៊ុនព្រៃនឌីស ធីមបើរ អិលធីឌីផ្ទៃដីទំហំ ៧.៨៩៦,១១ ហិកតា នៅខេត្តកំពង់ស្ពឺ តាម **លិខិតលេខ ១៥៦២ សជណ.បស្ក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩** |

**ផ្នែកទី៦-VI ៖ សំណូមពររបស់ក្រុមហ៊ុន៖**

ក្រុមហ៊ុនមានមោទនភាពចំពោះកិច្ចសហការ និងធ្វើការជាមួយគ្នាបានយ៉ាងល្អប្រសើរវាងភាគីពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនក៏នូវមានបញ្ហាប្រឈមមួយចំនួនស្នើសុំក្រសួង មន្ទីរ និងស្ថាប័នមានសមត្ថកិច្ចផ្តល់ការគាំទ្រ និងជម្រុញនីតិវិធីឱ្យទាន់ពេលវេលាដូចខាងក្រោម៖

១. ស្នើសុំក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រ និងជួយពន្លឿននីតិវិធីពិនិត្យ និងកែសម្រួលផែនការមេ ដោយអនុឡោមតាមទំហំផ្ទៃដី និងរយៈពេលវិនិយោគ ៥០ឆ្នាំ នៃកិច្ចសន្យាកែតម្រូវចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧

២. ស្នើសុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើថ្នាក់កណ្ដាល ខណ្ឌរដ្ឋបាលព្រៃឈើ ជួយជំរុញនីតិវិធីនៃការរៀបចំដាក់តំបន់អភិរក្សដែលក្រុមហ៊ុនទទួលខុសត្រូវការពារ និងអភិរក្ស ចូលជាស្ថានីយ ស្ដារព្រៃឈើឡើង ដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន

៣. ស្នើសុំកិច្ចអន្តរាគមន៍ផ្លូវច្បាប់លើករណីទន្ទ្រានយកដីសម្បទានរបស់ក្រុមហ៊ុនដែលបានអនុវត្តការចុះបញ្ជីដីរដ្ឋ និងរៀបចំអនុបយោគរួចរាល់ ពីប្រជាជនដូចបានបញ្ជាក់ខាងលើដោយខុសច្បាប់៕

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**នាយកប្រតិបត្តិ**

**Eugene Kraamwinkel**